ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខ: ៧២១១ ក.អ.ជ
ថ្ងៃទី
បញ្ជូន

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៩៦០ សជណ.ជហ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តម លោកជំទាវ សមាជិក សមាជិការាជរដ្ឋាភិបាល**
**នីតិកាលទី៥ នៃរដ្ឋសភា**

**កម្មវត្ថុ** : ករណីស្តីពីការបញ្ចប់សុពលភាព នៃការប្រើប្រាស់ស្លាកលេខរថយន្តរបស់សមាជិក សមាជិការាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា។

**យោង** : លិខិតលេខ ១៤០៣ លស.ជហ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា : ផ្លាកលេខរថយន្តរាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា ត្រូវបានបញ្ចប់សុពលភាព នៃការប្រើប្រាស់ហើយ ។ ក្នុងន័យនេះ សូមឯកឧត្តម លោកជំទាវ ដែលជាសមាជិក សមាជិការាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភាទាំងអស់ មេត្តាប្រគល់ផ្លាកលេខរថយន្ត ដែលអស់សុពលភាពប្រើប្រាស់នេះជូនមកការិយាល័យគ្រប់គ្រងរថយន្ត នៃទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានរួសរាន់ ។ ក្នុងករណីមានការបាត់បង់ផ្លាកលេខរថយន្តដោយប្រការណាមួយ សូមឯកឧត្តម លោកជំទាវ ត្រូវរាយការណ៍ជាលាយលក្ខអក្សរឲ្យបានជាក់លាក់អំពីមូលហេតុនៃការបាត់បង់នេះ។ ទីស្តីការគណៈរដ្ឋមន្ត្រី នឹងស្នើសុំភ្នាក់ងារមានសមត្ថកិច្ចឲ្យចាត់វិធានការបញ្ឈប់ និងដកហូតផ្លាករថយន្តលេខរាជរដ្ឋាភិបាលនីតិកាលទី ៤ ដែលកំពុងធ្វើចរាចរតាមដងផ្លូវនាពេលឆាប់ៗ ខាងមុខនេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមលោកជំទាវ មេត្តាជ្រាប និងចាត់ចែងអនុវត្តឲ្យបានល្អ។

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

គឹករ៉េត_សំរេច

ចម្លងជូន៖
- ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
«ដើម្បីជ្រាប និងចាត់វិធានការ»
- ឯកសារ កាលប្បវត្តិ